# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE

ឆ្នាំទី ២៤ ខែមករា លេខ ១

ព.ស. ២៤៩៤ — គ.ស. ១៩៥២

# ពុទ្ធសាសនាជិប្បាយ

ព្រះបាឡាត់ ឆ្វ-ឱម វត្តព្រះពុទ្ធមានបុណ្យ ក្រុងភ្នំពេញ

ទេសនាដាក់វិទ្យុឃោសនសព្ទនៃប្រទេសកម្ពុជា

កាលពីថ្ងៃ១៥រោច ខែផល្គុន ឆ្នាំកុរនព្វស័ក

ព.ស.២៤៩០ (៨-៤-៤៨)

ទស្សនាវដ្ដីកម្ពុជសុរិយា

ឆ្នាំទី២៤ ខែមករា លេខ១ ព.ស.២៤៩៤ គ.ស.១៩៥២

# ពុទ្ធសាសនជាតិប្បាយ

ព្រះបាឡាត់ ឆ្វ-ឱម វត្តព្រះពុទ្ធមានបុណ្យ ក្រុងភ្នំពេញ

ទេសនាដាក់វិទ្យុឃោសនសព្ទនៃប្រទេសកម្ពុជា

កាលពីថ្ងៃ១៥រោច ខែផល្គុន ឆ្នាំកុរនព្វស័ក

ព.ស.២៤៩០ (៨-៤-៤៨)

***

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្សការ ចំពោះព្រះដ៏មានបុណ្យ អរហន្តសម្មាសម្ពុទ្ធ អង្គនោះ (ព្រមទាំងព្រះធម៌និងព្រះអរិយសង្ឃដោយសេចក្ដីគោរព)។

វេលានេះ អាត្មាភាពនឹងសូមលើកយកផលប្រយោជន៍នៃពុទ្ធសាសនា មកអធិប្បាយដោយសង្ខេប ដើម្បីឲ្យពួកខេមរបុត្រ

ទាំងអស់ក្នុងកម្ពុជរដ្ឋ គិតជញ្ជឹងរំពឹងពិចារណា ក្នុងចិត្តគ្រប់ៗគ្នាឲ្យឃើញជាក់ច្បាស់ថា ជាសាសនាមានតម្លៃថ្លៃថ្នូរ ក្នុងផ្លូវលោកផង ផ្លូវធម៌ផង ជាសាសនាប្រដៅមនុស្សឲ្យភ្ញាក់កំណើតឆើតទៅមុខផង ជាសាសនាប្រដៅមនុស្សឲ្យចងសាមគ្គីធម៌គ្នា ជាលទ្ធិរួមសម្បាច់កាច់ឧបសគ្គណាមួយ ដែលជាគ្រឿងរារាំងក្នុងលោកផង ជាសាសនាអាចសង្កត់សង្កិននូវពួកជនដែលពួនតែខ្លួន យកសុខផ្ទាល់ខ្លួនតែម្នាក់ឯង ដូចសេចក្ដីដែលនឹងថ្លែងតទៅនេះ។

ក៏ពាក្យថាសាសនាៗនេះ គឺជាបង្គោលឬជាទីពឹងផ្អែកយ៉ាងសំខាន់ថ្លៃថ្លារបស់ពួកជនក្នុងសកលលោក តាំងពីបុរាណសម័យព្រេងនាយមក។ តួយ៉ាងដូចជនជាតិខេមរយើងនេះ សឹងជាអ្នកសម្ដែងសេចក្ដីគោរពរាប់អានដោយស្មោះត្រង់អស់ពីចិត្ត ចំពោះពុទ្ធសាសនា ខ្វល់ខ្វាយរក្សាគ្រប់ៗគ្នា អស់ចំនួនជាងពីរពាន់ឆ្នាំមកហើយ។

ពាក្យថា **សាសនា** នេះ ប្រែថា “វាចាជាគ្រឿងប្រៀនប្រដៅ” ឬថា “ពាក្យបណ្ដាំ” **ពុទ្ធ:** នេះជាឈ្មោះរបស់មហាវីរបុរសដែលបានប្រកាសសាសនា។

រួមពាក្យ ពុទ្ធ: និង សាសនា ទាំងពីរភ្ជាប់គ្នាជា ពុទ្ធសា-សនាៗ នេះ សម្គាល់សេចក្តីថា វាចាជាគ្រឿងប្រៀនប្រដៅរបស់ព្រះសក្យមុនីគោតមសម្ពុទ្ធ ដែលជាបុគ្គលឆ្នើមក្នុងត្រៃភព ដែលពុទ្ធបរិស័ទទាំងឡាយធ្លាប់គោរពរាប់អានរៀងៗមក ជាសាសនាយ៉ាងចំណានល្អចំណាប់ពន់ពេក ទុកឲ្យសត្វទាំងឡាយក្នុងសកលលោកប្រតិបត្តិតាមដោយមធ្យ័ត ដើម្បីនឹងកម្ចាត់សេចក្តីទុក្ខសោកគ្រប់យ៉ាង ហើយឲ្យបានសេចក្តីសុខក្សេមក្សាន្តយ៉ាងអស្ចារ្យ។

ព្រោះហេតុដូច្នោះ ព្រះពុទ្ធបាននាមប្រាកដថា ជាម្ចាស់នៃសាសនា គឺព្រះធម្មសាមី ព្រោះទ្រង់ព្រះមេត្តានឹងប្រោសប្រាណព្រះរាជទានទូវព្រះធម៌ដែលទុកជាច្បាប់ដ៏ថ្កើងថ្កាន ឲ្យសត្វកាន់តាមលំអានឋានន្តរៈនិងតម្លៃថ្លៃថ្នូររបស់ខ្លួន។

នរជនណា ដែលមានសន្តានចិត្តជោកជាប់នៅក្នុងលោកនេះខ្លាំងក្រាស់ក្រួនហួសប្រមាណពេក គឺថាមានចិត្តជ្រុលជ្រប់ងក់ងោកមិនគិតខ្លួន គេអង្រួន់មិនញ័រមិនរង្គើ ព្រះអង្គក៏ទ្រង់ប្រោសព្រះរាជ-ទានធម៌យ៉ាងជាន់ទាប ឲ្យត្រូវតាមអធ្យាស្រ័យតាមសភាព តាមបែបនៃនរជននោះ ឲ្យយ៉ាងធូរៗ ល្មមៗ ពីរោះស្តាប់ សង្គ្រោះតាមភាពនៃ

មនុស្សដែលមានឥន្ទ្រិយអន់ ទ្រង់ប្រដៅឲ្យប្រកបការងារក្នុងបច្ចុប្បន្ន ដែលជាប្រយោជន៍ឃើញជាក់ទាន់ហាន់នឹងភ្នែក ឲ្យបានស្រាកស្រាន្ត ចាកសេចក្ដីទុក្ខបានសុខគ្រប់ៗប្រាណ។

ប៉ុន្តែក្នុងពេលនេះ នឹងសូមលើកយកផលប្រយោជន៍យ៉ាង សំខាន់របស់មនុស្សក្នុងបច្ចុប្បន្នមកចង្អុលបង្ហាញ ឲ្យឃើញជាក់ ច្បាស់គ្រប់ៗគ្នាយ៉ាងនេះថា:

១–កើតមកជាមនុស្ស ត្រូវតែឲ្យមានសេចក្ដីព្យាយាមប្រឹង ប្រែងជ្រៀតជ្រៀតប្រជែងធ្វើការងារចិញ្ចឹមជីវិត កុំខ្ជិលច្រអូស កុំ ថយក្រោយឲ្យសោះ ត្រូវតែរុករកកុំរួញរា។

២–ត្រូវឲ្យមានសីលធម៌ក្នុងចិត្ត និងត្រូវឲ្យស្រឡាញ់សេចក្ដី ស្ងប់រៀបរយ កុំនិយាយពាក្យនាំឲ្យបែកសាមគ្គីធម៌។

៣–ត្រូវឲ្យប្រតិបត្តិតាមច្បាប់ សម្រាប់ស្រុកដោយហ្មត់ចត់ ជួយគយគន់រកមើលហើយបង្ហាញ កុំទុកលាក់មនុស្សធ្វើខុសច្បាប់ ផ្សេងៗ និងអ្នកមានចិត្តក្បត់ចំពោះម្ចាស់ផែនដី ដែលព្រះអង្គទ្រង់ ទសពិធរាជធម៌មានទឹកព្រះរាជហឫទ័យ ពោលគឺមេត្តាផ្សាយទៅលើ នាហ្មឺនសព្វមុខមន្ត្រីនិងអាណាប្រជានុរាស្ត្រទាំងអស់។

៤–ត្រូវស្រឡាញ់ប្រទេសជាតិ សាសនា មហាក្សត្រ ហើយខំនាំគ្នារក្សាស្រុកទេសរបស់ខ្លួន ត្រូវពួតដៃគ្នាការពារអន្តរាយគ្រប់ផ្លូវ ដើម្បីធ្វើប្រទេសជាតិយើងឲ្យចម្រើនរុងរឿងទាន់នានាជាតិជុំខ្លួន។

៥–ត្រូវមានសេចក្តីចេះដឹងចូលចិត្តក្នុងផ្លូវរដ្ឋនិយម ហើយខំនាំគ្នាប្រតិបត្តិឲ្យបានផលប្រយោជន៍ទាន់ភ្នែក កុំឲ្យជាតិដ៏ទៃហៅទៅប្រើដូចជាគោក្របី។

៦–ត្រូវឲ្យចេះប្រើសិទ្ធិអំណាចស្មើភាគគ្នា និងសេចក្តីគោរពតាមសមគួរដល់ច្បាប់និងប្រវេណីនិយម ដែលឥតទាស់ខុសនឹងច្បាប់។

៧–ត្រូវឲ្យយកចិត្តទុកដាក់ ក្នុងការធ្វើស្រែចម្ការច្បារដំណាំដ្បិតការធ្វើរបរនេះ មានប្រយោជន៍ដល់ប្រទេសជាតិនិងរាជការរដ្ឋ-បាលជាសំខាន់បំផុត។

៨–មាតាបិតាត្រូវដឹកនាំបង្ហាត់បុត្រប្រុសស្រី ឲ្យខិតខំរៀនសូត្រចំណេះវិជ្ជាមានលេខនិងអក្សរជាដើម ដែលជាផ្លូវលោកគ្តី ផ្លូវធម៌គ្តី កុំបណ្តែតបណ្តោយឲ្យកូននៅល្ងង់ខ្លៅ ព្រោះការដែលសិក្សាវិជ្ជា ក៏ដើម្បីឲ្យកើតបញ្ញា គិតឃើញដោយខ្លួនឯងក្នុងមួយថ្ងៃៗ មិនមែន

សម្រាប់តែយកកាកគំនិតរបស់គេមកប្រើគ្រប់យ៉ាងនោះទេ។

៩–សូមឲ្យពួកខេមរបុត្រគ្រប់ស្រុកគ្រប់ភូមិ-ធំតូច ខំបោសសម្អាតទីភូមិស្ថានផ្ទះសម្បែង កន្លែងដេក-អង្គុយ គ្រឿងបរិភោគ គ្រឿងស្លៀកពាក់ គ្រឿងប្រើប្រាស់គ្រប់មុខជាដើម និងសម្អាតកូនចៅធំ-តូចកុំឲ្យមានកើតកមរមាស់តាមវិធីអនាម័យផ្សេងៗ។

អាត្មាភាពដែលសម្តែងពន្យល់អស់លោក-អ្នកយ៉ាងនេះ មិនមែនជាការទាស់ខុសនឹងព្រះពុទ្ធដីកាទេ ព្រោះព្រះអង្គទ្រង់សម្តែងពន្យល់អំពីប្រយោជន៍បច្ចុប្បន្ន ល្អិតជាងនេះទៅទៀតរហូតដល់ទ្រង់ហាមមិនឲ្យចាយវាយទ្រព្យសម្បត្តិខ្ជះខ្ជាយហួសប្រមាណពេក។

នែពួកខេមរបុត្រ ! បើអ្នកពិតជាខេមរសុទ្ធមែន ចូរអ្នកប្រុងប្រយ័ត្នគោរពប្រតិបត្តិឲ្យមាំមួន តាមខទាំង៩យ៉ាងដូចអាត្មាភាពបានអធិប្បាយញែកចេញមកនេះ ប្រទេសរបស់អ្នកក៏នឹងបានសេចក្តីចម្រើនសប្បាយយ៉ាងទូលំទូលាយច្រើន ឥតមានទុក្ខភ័យអ្វីមកបៀតបៀនបាន ដោយសារតែអ្នក, បើប្រសិនជាកូនកម្ពុជាទាំងឡាយ នៅធ្វើសោះអង្គើយកន្តើយមិនខំខ្មីឃ្មាតគោរពចំពោះជាតិ សាសនា មហាក្សត្រទេ នោះកុំសង្ឃឹមថាប្រទេសយើងនឹងមានតម្លៃស្មើនឹង

ប្រទេសជាតិដទៃឡើយ។

ហេតុនេះ សូមឲ្យកូនកម្ពុជាទាំងឡាយ តាំងចិត្តគោរពរាល់យប់ព្រឹក ប្រុងស្មៀតប្រុងគំនិតគិតជានិច្ចជាអាលជ្ជី ចំពោះជាតិសាសនា មហាក្សត្ររបស់យើង កុំឲ្យមានលោះពេលវេលាឡើយ ប៉ុន្តែមានជនជាតិខេមរៈខ្លះមិនតាំងចិត្តគោរពសោះ បែរទៅជាមានចិត្តក្បត់ទៅវិញ បើម្លឹងៗ តើជាតិប្រទេសរបស់យើងនឹងថ្កើងអំពីផ្លូវណា?

កូនកម្ពុជាគោងអ្នកសង្កេតគ្រប់គ្នា ឲ្យឃើញជាក់ច្បាស់ទៅចុះ កុំនៅទ្រមក់ពួនតែខ្លួនយកសុខផ្ទាល់តែម្នាក់ឯង ឃើញទេជាតិដទៃដែលគេបានសេចក្ដីសុខ-ចម្រើន មកអំពីគេមិនដេកធ្មេចដូចយើងៗគួរភ្ញាក់កំណើត ហើយកុំនៅដេកលក់ដល់ណាទៀត។

កូនកម្ពុជាទាំងឡាយ ! បើអ្នកចង់ឲ្យប្រទេសរបស់អ្នករុងរឿងទៅថ្ងៃមុខ គោងអ្នកខំផ្សាំភ្ញាស់បណ្ដុះពូជ ពោលគឺវិជ្ជាចំណេះដែលបុគ្គលត្រូវស្វែងរករៀនសូត្រក្នុងលោក មិនត្រូវដំអក់ទម្រន់ទ្រមឹងទ្រមើយមិនបើកភ្នែកមើលទេ ព្រោះកម្ពុជរដ្ឋរាជធានី អស់លោករាជការធំៗ បានបន្ទំវិជ្ជាភ្លឺព្រោងព្រាត ត្រូវកូនកម្ពុជា ខំនាំគ្នាឆ្លៀត

រៀនសូត្រឡើង កុំស្ទាក់ស្ទើរដល់ណាទៀត។ កូនកម្ពុជាទាំងឡាយ ! អ្នកគង់យល់ច្បាស់ថា "ពោះរស់ពីបាយ" រាងកាយនេះហើយដែលជាជម្រុកសម្រាប់ផ្ទុកវិជ្ជាសព្វគ្រប់ប្រការ ប្រសិនណាជារូបនេះ ដល់នូវភាពវិកលវិការដោបដល់ស្គាំងស្គមទាំងសង្ខារហើយ បុគ្គលមិនបានព្យាយាម ព្យាបាលបរិហារទេ ចំណេះវិជ្ជាគ្រប់យ៉ាងក៏មិនចេះ។

យើងបានដឹងជាក់ថា រូបនេះរស់ដោយអាហារពិត ថាបើមិនគិតរកចំណេះទេ បើរោគវាមកប្រជុំរឹតរុំពុំរបេះ ពិតជាមាត់លិទ្ធដេះមិនលែងឡើយ។

ត្រង់ន័យនេះ សូមបញ្ជាក់ថា មានជនចំពូកខ្លះ ស្នេហានឹងនគរកាយរបស់ខ្លួនដែរ តែដំអក់ទម្រន់មិនខំរៀនវិជ្ជាមិនខំការពារទេ ទុកបណ្ដោយឲ្យនគរកាយរបស់ខ្លួននៅជាល្ងង់ខ្លៅ ធ្លាក់ទៅជាខ្ញុំគេ តែមានចិត្តនោះពុះក្ដៅទៅ ដោយអំណាចឧបក្កិលេសទាំង១៦ប្រការ និងអកុសលចេតសិក១៤ប្រការ ជាមេបណ្ដាលដឹកនាំមនុស្សឲ្យប្រព្រឹត្តល្មើស នាំឲ្យជ្រួលច្រាល់អន្ទះសា នាំឲ្យប្រាថ្នាធំហួសហេតុ ទៅជាចង់សោយរាជ្យជាស្ដេច នេះដោយអំណាចសេចក្ដីល្ងង់ខ្លៅ។ ខ្លះទៅជាធរាស្ត្របាំងហ្លួង លួចប្លន់ទ្រព្យ បង្កើតធ្វើទំពតាំងតួរបស់ខ្លួនត

នឹងម្ចាស់ផែនដី ខ្លះទៅជាធ្វើឲ្យកើតកលិយុគ ចាក់រុករករឿងរកហេតុ ធ្វើឲ្យពួករដ្ឋបាលកើតសេចក្តីរំខាន ទាំងនេះព្រោះសេចក្តីល្ងង់ខ្លៅ គឺអវិជ្ជាបាំងបិទមិនឲ្យគិតពិចារណាឃើញល្អបាន បែរទៅជាវង្វេងវល់ចិត្តឥតចេះស្វាង កសាងតែបាបកម្មសព្វឥតស្កប់សោះ ធ្វើឲ្យទើសទាស់អំពល់ចិត្ត រួបរឹតដល់រាងកាយថែមទៀត ក្លាយទៅជាជាប់ទោសដល់ឧក្រិដ្ឋ ហ្នឹងហើយផលនៃសេចក្តីល្ងង់ខ្លៅ ដែលជាផលនាំឲ្យខាតបង់ប្រយោជន៍ក្នុងលោកនេះ លុះដល់ទម្លាយរាងកាយអំពីលោកនេះទៅនឹងនាំប្រាណឲ្យទៅជ្រកករកអបាយមិនខាន។

ហេតុនេះ កូនកម្ពុជាទាំងឡាយ មិនត្រូវប្រមាទមើលងាយសាសនា មហាក្សត្រទេ ត្រូវតែគោរពប្រណិប័តន៍ថ្វាយបង្គំរំឭករាល់យប់ថ្ងៃ ទើបពេញជាអ្នកមានកតញ្ញូកតវេទីចំពោះសាសនា មហាក្សត្រមែន ព្រោះព្រះអង្គជាបុព្វការីលើមន្ត្រីនិងប្រជារាស្ត្រទាំងអស់ ព្រមទាំងមានទសពិធរាជធម៌ទាំង១០យ៉ាងនិងព្រហ្មវិហារ៤ ជាប្រមុខរបស់ទ្រង់ បានជាមាននាមប្រាកដថា (រាជូបការោ) ទ្រង់ចាត់ជាបុព្វការី។

សេចក្តីដែលបានរៀបរាប់មកខាងលើនេះ ជាឈ្មោះនៃពាក្យ

ថា សាសនា មានតម្លៃថ្លៃថ្នូរថ្លៃថ្លា សម្មតា សន្មតថាចប់ដោយ សង្ខេបប៉ុណ្ណោះ ឯវំ។

—ចប់—

***

| |
|---|
| សូវឲ្យគេសរសើរ ប្រសើរជាងឲ្យគេអាណិត |
| សូវឲ្យគេថាមានចិត្ត ប្រសើរជាងគេថាខ្ជិល។ |
| យូរ - អ៊ុន |

***

Khmer K21
News & Media Website

ស្រាវជ្រាវដោយៈ ជាច់ សុតឹម